ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំព្រហ្មទណ្ឌ

លេខ:១៥៣/១៣-០២-២០១៣

សាលដីកា

លេខ:៤៤ក្រ.ឧក/១៨-០៦-២០១៣

តាងនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៩ខែមិថុនា ឆ្នាំ២០១៣ដោយមានសមាសភាពដូចតទៅ:

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

លោក [redacted]

ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខ ១៥៣ ចុះថ្ងៃទី១៣-០២-២០១៣ រវាង៖

១-ជនជាប់ចោទឈ្មោះ [redacted] ហៅស្រីនាង ភេទស្រី អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើតនៅស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង និងទីលំនៅបច្ចុប្បន្នផ្ទះលេខ២១៨ ផ្លូវលេខ៨៦ ភូមិ២២ ក្រុម២៧៧ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រស់)ម្តាយឈ្មោះ [redacted] (រស់) ប្តីឈ្មោះ [redacted] កូន០១នាក់ ទោសពីមុនគ្មាន ។ ឃុំខ្លួនថ្ងៃទី០៤-០៩-២០១២ (ដើមបណ្តឹងឧទ្ធរណ៍)

មេធាវីការពារលោក [redacted] លោក [redacted]

២-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ៥៦ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើតនៅភូមិឫស្សីក្រោក ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ និងទីលំនៅបច្ចុប្បន្នផ្ទះលេខ២១៨ ផ្លូវលេខ៨៦ ភូមិ២២ ក្រុម២៧៧ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] ស្លាប់) ប្រពន្ធឈ្មោះ [redacted] កូន០១នាក់ ទោសពីមុនគ្មាន ។ ក្រៅឃុំ (ដើមបណ្តឹងឧទ្ធរណ៍ )

មេធាវីការពារលោក [redacted] ,លោក [redacted]





Scanned by CamScanner

៣-ជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ។ (គេចខ្លួន)

៤-ជនជាប់ចោនទឈ្មោ[redacted]ប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ។ (គេចខ្លួន)

ត្រូវចោទពីបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់បុប្ផា ទីតាំងផ្ទះលេខ៩ ផ្លូវ៨៦ ភូមិ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែ សីហា ឆ្នាំ ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២១៧ និងមាត្រា២១៨នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ភេទប្រុស អាយុ២៨ឆ្នាំ ទីលំនៅបច្ចុប្បន្នផ្ទះជួល ផ្លូវលេខ៨៦ ភូមិ១២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

មេធាវី លោក [redacted]

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]ភេទប្រុស អាយុ២៥ឆ្នាំ ទីលំនៅបច្ចុប្បន្នផ្ទះជួល ផ្លូវលេខ៨៦ ភូមិ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

មេធាវីលោ[redacted]

## **<u>រឿងហេតុមានដូចតទៅ</u>**

កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១២ វេលាម៉ោង១៩និង១០នាទី នៅមុខផ្ទះសំណាក់បុប្ផា មានករណីហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស មួយបានកើតឡើងដែលមានឈ្មោះ [redacted]និងប្តីបាននាំបងប្អូនឈ្មោ[redacted]និងឈ្មោ[redacted]បានដើរសំដៅទៅជនរងគ្រោះឈ្មោះ [redacted]និងឈ្មោះ [redacted] ដែលអង្គុយចាំម៉ូយនៅនឹងកន្លែងកើតហេតុខាងលើ ពេលនោះឈ្មោះ [redacted]បានចាប់ក្រៀកឈ្មោះ [redacted]ហើយយកទូលីវែសចាក់នៅលើក្បាលបណ្តាលឲ្យរងរបួសជាច្រើនកន្លែងនិងចាក់ចំខ្នង ចំបោះដៃផុតចំនួន០១កន្លែង រីឯឈ្មោ[redacted]បានយកពូថៅកាប់ទៅលើឈ្មោះ [redacted]ចំក្បាលរបួស០២កន្លែងបណ្តាលឲ្យហូរឈាម ភ្លាមៗនោះឪពុករបស់ឈ្មោ[redacted] និងអ្នកជិតខាងបានចូលឃាត់ចាប់ជនល្មើសម្នាក់ឈ្មោ[redacted]ក៏ឈ្មោ[redacted]ជាបងស្រីបង្កើតរបស់ឈ្មោះសិទ្ធ និងប្តីបានមកជួយរំដោះប្អូនឲ្យរួចគេចខ្លួនបាត់អស់ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១០៧(យ) ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារសេចក្តីសំរេចដូចតទៅៈ

១-ផ្តន្ទាទោសលើជនជាប់ចោទដូចខាងក្រោមៈ

-ឈ្មោះ: [redacted]ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៣ឆ្នាំ (បីឆ្នាំ) (កំពុងជាប់ឃុំ ) ។

-ឈ្មោះ:[redacted] ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៣ឆ្នាំ(បីឆ្នាំ) ( កំពុងរត់គេចខ្លួន ) ។

-ឈ្មោ[redacted]ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៣ឆ្នាំ(បីឆ្នាំ) ( កំពុងរត់គេចខ្លួន ) ។

Scanned by CamScanner

-ឈ្មោះ[redacted] ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៣ឆ្នាំ(បីឆ្នាំ ) តែឲ្យទទួលទោសតុកព្យួរទាំងអស់ ។

ត្រូវចោទពីបទៈហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខផ្ទះសំណាក់បុប្ផា ទីតាំងផ្ទះលេខ៥ ផ្លូវ៨៦ ភូមិ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១២ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា១០៦ មាត្រា១០៧មាត្រា១០៨ និង មាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ[redacted] ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ ឈ្មោះ[redacted] ភេទប្រុស អាយុ៥៦ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ[redacted] ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ និង ឈ្មោះ[redacted] ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ រួមគ្នាសងសំណងអន្តរាយផ្សេងៗ និងជម្ងឺចិត្តដល់ដើមបណ្តឹង និងជាជនរងគ្រោះចំនួនសរុបដូចខាងក្រោម ៖

-ឈ្មោះ[redacted]ហៅចន ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ ចំនួន៣០.០០០.០០០៛(សាមសិបលានរៀល)

-ឈ្មោះ[redacted] ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ ចំនួន៣០.០០០.០០០៛ (សាមសិបលានរៀល)។

ដើមបណ្តឹងរដ្ឋប្បវេណីទាមទារលើសពីនេះបដិសេធចោល ។

តាមមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-បង្គាប់ឲ្យចាប់ខ្លួនឃុំខ្លួនឈ្មោះ [redacted] ភេទប្រុស អាយុ៣០ឆ្នាំ និងឈ្មោះ[redacted] ភេទប្រុស អាយុ២៧ឆ្នាំ( មានអត្តសញ្ញាណដូចខាងលើ ) នៅពន្ធនាគារម១ ព្រៃស នៃក្រសួងមហាផ្ទៃ ។

តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤-សាលក្រមនេះ ជំនុំជំរះជាសាធារណៈនាថ្ងៃទី២៦, ២៧ ខែធ្នូ ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ[redacted], មេធាវីជនជាប់ចោទទាំងពីរនាក់ ដើមបណ្តឹង និងជនរងគ្រោះឈ្មោះ[redacted],ឈ្មោះ [redacted],មេធាវី ការពារដើមបណ្តឹង និង កំបាំងមុខជនជាប់ចោទឈ្មោះ[redacted]និង ឈ្មោះ [redacted]ដោយប្រកាសជាសាធារណៈ នៅថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១២ ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

បានឃើញសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៣-០១-២០១៣ របស់លោកមេធាវី[redacted] និងសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨-០១-២០១៣លោកមេធាវី[redacted]និង លោក[redacted] ការពារក្តីឲ្យឈ្មោះ[redacted]និង [redacted]ប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ១០៧ (យ) ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ គ្រប់ចំណុចទាំងមូលនៃសាលក្រម។ បណ្តឹងនេះធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបានយោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បានឃើញរបាយការណ៍របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ



Scanned by CamScanner

## <u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយបញ្ជាក់ថា ខ្លួនមានមុខរបរជាជាងដេរនៅសហគមន៍ ។ នៅថ្ងៃកើតហេតុខ្លួនដើរហាត់ប្រាណម្នាក់ឯងម៉ោងប្រហែល៦ ទៅម៉ោង៧ ហើយដើរទៅឈរនិយាយលេងជាមួយឈ្មោះ [redacted]នៅមុខផ្ទះគាត់ ពេលនោះប្ដីរបស់ខ្លួននៅទីនោះដែរ។ បន្ទាប់ពីនិយាយគ្នាបានប្រហែល២០នាទីខ្លួនបានឮសំលេងឈ្លោះគ្នាហើយមានគេប្រាប់ថា មនុស្សវាយគ្នាក្នុងផ្ទះសំណាក់បុប្ផាមានចំងាយពីកន្លែងខ្លួនឈរប្រហែល១៨ម៉ែត្រ ទៅ ២០ម៉ែត្រ ខ្លួនបានដើរទៅមុខបន្តិចឈរពីចំងាយឃើញមិនច្បាស់មុខអ្នកវាយគ្នានិងសកម្មភាពនោះទេ ព្រោះទីនោះអំពូលភ្លើងមូលងងឹតព្រាលៗហើយមនុស្សច្រើនពេកក៏ត្រឡប់មកផ្ទះ[redacted]ញខ្លួនទទួលស្គាល់ថា បានស្រែកថាប្រុសៗមានកំលាំងជួយឃាត់គ្នាផងនេះជាវប្បធម៌ខ្មែរ តែខ្លួនមិនបានចូលជួយឃាត់ទេ។ក្រោយកើតហេតុចប់មានមនុស្សប្រុសម្នាក់បានមកចង្អុលមុខចោទប្រកាន់ខ្លួនថាហៅគេឲ្យមកវាយកូនគាត់ហើយខ្លួនបានប្រកែកថាខ្លួនមិនបានធ្វើអ្វីទេ។ រឿងទំនាស់វាយគ្នាមិនមែនតែខ្លួនទេ ដែលមិនស្គាល់មុខអ្នកវាយគេ សូម្បីប្រជាជនក្នុងភូមិក៏គ្មានអ្នកណាស្គាល់ដែរ។ រឿងខ្លួនត្រូវគេចោទប្រកាន់ នេះគឺមកពីគេស្អប់ព្រោះខ្លួនជាអ្នកតស៊ូទាមទារដីបឹងកក់ ហើយកើតរឿងវាយគ្នារួចហើយប៉ូលីសមិនដែលហៅខ្លួនសាកសួរទេ ដល់ប្រហែលមួយខែក្រោយមក ទើបហៅខ្លួនឲ្យទៅធ្វើអត្តសញ្ញាណបណ្ណ័ហើយឃុំខ្លួនតែម្ដង។ ខ្លួនបដិសេធការចោទប្រកាន់ ដោយខ្លួនមិនបានចូលទៅប្រឡេះដៃអ្នកម៉ូតូឌុបដោះលែងប្អូនខ្លួនទេ មានឈ្មោ[redacted]សាក្សី ហើយប្អូនប្រុសរបស់ខ្លួនមិនមានរស់នៅជាមួយខ្លួនទេ។ នៅថ្ងៃកើតហេតុមិនដឹងថាជាប្អូនខ្លួនឬមិនមែន ខ្លួនមិនដឹងហើយកញ្ចក់ឡានរបស់បងស្រីខ្លួនបាត់បីដងមិនចាំថ្ងៃទេ តែរឿងនេះបានប្ដឹងប៉ូលីសហើយ។ឈ្មោះ[redacted]និង[redacted]ឈប់រស់នៅជាមួយខ្លួនឆ្នាំ២០០២ហើយ ធ្លាប់មកលេងជាមួយខ្លួនយូរៗម្ដងដែរ តែមិនដឹងពួកគេរស់នៅឯណាទេ ។ សំណូមពរសុំតុលាការលើកលែងចោទប្រកាន់

-ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយបញ្ជាក់ថា នៅថ្ងៃកើតហេតុវេលាម៉ោង៦ទៅ៧ ខ្លួនជិះម៉ូតូបំរុងទៅទិញឥវ៉ាន់ហើយបានជួប[redacted]នៅអង្គុយមុខផ្ទះគាត់ក៏ចុះមកឈរនិយាយជាមួយគាត់ដោយបែរមុខមកទិសខាងលិចបន្ទាប់មកប្រពន្ធខ្លួនមកដល់ហើយនិយាយសួរនាំពីរឿងដីក៏ឮគេឈ្លោះគ្នា ខ្លួននិងប្រពន្ធខ្លួនបានបែរទៅមើលមិនបានចូលទៅទេ។ ប្រហែល២០នាទីក្រោយមកស្រាប់តែមានមនុស្សម្នាក់មកស្រែកថា ប្រពន្ធរបស់ខ្ញុំនាំគេមកវាយកូនគាត់ តែឈ្មោ[redacted]បានឆ្លើយថា អ្នកឯងកុំមកចោទគាត់ទាំងពីរនាក់ប្ដី ប្រពន្ធនៅឈរទីនោះរហូត។ នៅកន្លែងកើតហេតុភ្លើងអំពូលមូលតូចភ្លឺមិនច្បាស់ មិនស្គាល់អ្នកវាយគ្នាទេ ហើយខ្លួន និងប្រពន្ធខ្លួនមិនបានចូលជួយទេ គ្រាន់តែប្រពន្ធខ្លួនបានស្រែកឲ្យគេជួយ។ ក្នុងឆ្នាំ២០១០ ខ្លួនមករស់នៅបឹងកក់ពុំមានប្អូនថ្លៃខ្លួនទាំងពីរ នាក់មកលេងទាល់តែសោះ ហើយអ្នកទាំងពីនេះខ្លួនស្គាល់ច្បាស់។ ពាក់ពន្ធ័រឿងបាត់កញ្ចក់ឡានខ្លួនមិនដឹងអ្នកណាលួចទេ ហើយខ្លួនបានប្ដឹងប៉ូលីសប៉ុស្ដិ៍រួចហើយ តែវាជារឿងដោយឡែកហើយរឿងនេះគឺប៉ូលីសជាអ្នកធ្វើឡើងព្រោះប្រពន្ធខ្លួនជាសកម្មជនរឿងកា់ដីធ្លី។ពេលទៅមើលគេឈ្លោះគ្នាប្រពន្ធខ្លួនដើរមុនហើយឈរមើលពីចំងាយប្រហែល៥ម៉ែត្រ ឃើញគេប្រតាយប្រតប់គ្នាឃើញជនរងគ្រោះមានឈាមដែរ គឺខ្លួនឃើញជនរងគ្រោះដើរមកឈរមុខខ្លួន ហើយគេពុំមានថា ខ្លួននិងប្រពន្ធនាំគេមកវាយទេ។ក្នុងផ្ទះកើតហេតុខ្លួនមិនច្បាស់មិនដឹងថាមានមនុស្សសរុបប៉ុន្មានអ្នក

Scanned by CamScanner

ទេ ខ្លួនឃើញតែអ្នកប្រតាយគ្នាខាងក្រៅពីរនាក់តែមិនស្គាល់ ។ ខ្លួនស្គាល់ប្អូនថ្លៃកាលវានៅតូចដល់វាធំមិនដែលឃើញ ហើយខ្លួនរៀបការជាមួ[redacted]២០០១-២០០២ ។ ហេតុការចប់ពុំឃើញជនល្មើសត្រូវបានគេចាប់ទេ ហើយកន្លែងកើតហេតុមានអ្នកស្រែកឲ្យជួយជាសំលេងមនុស្សស្រី ។ នៅសាលាដំបូងខ្លួនឆ្លើយពីរដង ហើយចម្លើយនោះខ្លួនឆ្លើយថា បំរុងចូលឃាត់ប៉ុណ្ណោះ។ សំណូមពរសុំជួយរកយុត្តិធម៌ឲ្យខ្លួននិងប្រពន្ធ និងសុំលើកលែងចោទប្រកាន់។

បានឃើញចម្លើយជនរងគ្រោះ[redacted]នឆ្លើយបញ្ជាក់ថា នៅថ្ងៃកើតហេតុថ្ងៃទី០៧-៨-២០១២ វេលាម៉ោង៧,១០នាទី ខ្លួនអង្គុយចាំម៉ូយម៉ូតូឌុបនៅមុខផ្ទះសំណាក់បុប្ផា ហើយមិត្តភ័ក្តខ្លួនឈ្មោះ[redacted]បានហៅខ្លួនហូបស្រាថ្នាំជាមួយក្នុងផ្ទះសំណាក់បុប្ផា ពេលនោះបានឃើញឈ្មោះ[redacted]និងប្តីគាត់បាននាំប្អូនគាត់ឈ្មោ[redacted]នៅមុខផ្ទះសំណាក់មកចង្អុលខ្លួនហើយប្អូនគាត់ចូលមកចាក់ខ្លួន។ ខ្លួនបានរត់ចូលក្នុងបន្ទប់អ្នកស្រីចាន់បុប្ផាតែត្រូវឈ្មោះកន្លង់វាយទ្វារចូលចាក់ខ្លួនបន្ថែមនឹងទូលីវីស ហើយឳពុករបស់ខ្លួននិងឈ្មោ[redacted]លមកជួយចាប់បានឈ្មោ[redacted]ជាប់ តែត្រូវឈ្មោះ[redacted]ជួយប្រឡេះដៃចេញ ហើយឈ្មោះ[redacted]នបានចូលឃាត់ទេ ឯប្តីគាត់ខ្លួនមិនបានចាប់អារម្មណ៍ ។ខ្លួនស្គា[redacted]ាស់ ពីព្រោះខ្លួនជួលផ្ទះនៅជិតផ្ទះគាត់ប្រាំ-ប្រាំមួយឆ្នាំ ហើយឈ្មោ[redacted]ក្មេងប្រុសម្នាក់ស្រែកប្រាប់ ថ្ងៃនោះខ្លួនមិនសន្លប់ទេ ហើយក៏មិនស្គាល់ប៉ូលីសប៉ុស្តិ៍ដែរ។ ខ្លួនសំអាងលើសាក្សីឈ្មោ[redacted] ហើយអ្នកស្រែកឲ្យជួយមិនដឹងអ្នកណាទេ។ ពេលគេវាយខ្លួនមនុស្សក្នុងផ្ទះមានចំនួន៦-៧នាក់ហើយផ្ទះនោះដាក់ភ្លើងអំពូលម៉ែត្រទើបខ្លួនស្គាល់ឈ្មោ[redacted]ស់ ខ្លួនមិនដែលទាស់គ្នាជាមួយ[redacted]ទេ។ គេចាក់ខ្លួនចំខ្នងមួយទូលីវីស ចំក្បាលបួនទូលីវីសហើយម្ចាស់ផ្ទះសំណាក់បុប្ផាមិននៅផ្ទះទេគឺមានតែអ្នកចាំផ្ទះ។

បានឃើញចម្លើយជនរងគ្រោះឈ្មោះ[redacted]បានឆ្លើយបញ្ជាក់ថា ពេលកើតហេតុខ្លួនផឹកស្រាជា[redacted] បានឃើ[redacted]និង ប្តីគាត់នៅខាងក្រៅចង្អុលមកខ្លួនហើយដល់គាត់ចេញប្អូនគាត់មកតែខ្លួនមិនបានឮឈ្មោះបុប្ផាបញ្ជាប្អូនទេ។ ប្អូនរបស់[redacted]លទាំងពីរនាក់មកដល់កាប់ចាក់តែម្តង ហើយពួកខ្លួនរត់ចូលក្នុងបន្ទប់ពួកគេរត់តាមចូលបន្ទប់ដែរ ហើយពេលខ្លួនចេញមកវិញបានឃើញឪពុ[redacted]កចាប់បានអ្នកចាក់ថៃសេង ខ្លួនឮ[redacted]ប្តីគាត់ស្រែកថា ខ្ញុំឲ្យវាយចោរលួចកញ្ចក់ឡាន រួចឃើញប្រលេះ[redacted]បងប្អូនគាត់។

បានឃើញចម្លើយសាក្សីឈ្មោ[redacted]ានឆ្លើយបញ្ជាក់ថា ខ្លួនជាឪពុកជនរងគ្រោះ[redacted] នៅថ្ងៃកើតហេតុខ្លួននៅរត់ម៉ូតូឌុបចំងាយពីកន្លែងកើតហេតុប្រហែល៣០ម៉ែត្រ ស្រាប់តែមានក្មេងរត់មកប្រាប់ថាជួយបងចិត្តផងគេកាប់ងាប់ហើយទើបខ្លួនរត់ទៅឃើញគេគ្រៀកកកូនកំពុងចាក់បុកនឹងទូលីវីស។ ក្មេងស្រីរត់មកប្រាប់ខ្លួនឈ្មោ[redacted]អាយុ២០ឆ្នាំ ហើយពេលខ្លួនមកដល់ក៏យស្ទន់ស្ទោចាប់អូសកូនចេញឃើញមានស្នាមចំទូលីវីស ហើយឃើញម្នាក់ទៀតឈ្មោ[redacted]នកាប់លើ[redacted] ខ្លួនឃើញឈ្មោ[redacted]ចេញក៏រត់តាមហូតទើបឈ្មោ[redacted]ឈ្មោះនេះបាន តែពេលនោះ[redacted]ងប្តីចូលមកប្រតាយជាមួយ[redacted]ប្រលេះដៃចេញតែមិនដឹងជួយ[redacted]ឯខ្លួនបន្តរត់តាមចាប់ឈ្មោ[redacted]ាប់មិនបាន។ខ្លួនមានផ្ទះជួលនៅម្តុំផ្ទ[redacted]ានស្គាល់គាត់ច្បាស់តាំងពីមុនពេលកើតហេតុម្លេះ។មុនកើតហេតុខ្លួនមិនស្គាល់ប្អូន[redacted]តែខ្លួនធ្លាប់ឃើញម្តងពេលវាមានទំនាស់



Scanned by CamScanner

ជាមួយផ្ទះសំណាក់សួស្តី។ពេលខ្លួនដើរចូលជួយកូនពុំបានចាប់អារម្មណ៍ [redacted] ប្តីនៅទីនោះទេ ដល់ក្រោយមកទើបឃើញបុប្ផានិងប្តីគាត់ប្រគាយជួយអ្នកកាន់ពូថៅ។ព្យាបាលឈ្មោះ [redacted] រុបអស់ប្រហែលជាងបីពាន់ដុល្លាអាមេរិក។

បានឃើញចម្លើយសាក្សីឈ្មោ [redacted] បានឆ្លើយបញ្ជាក់ថា ខ្លួនមិនចាំថ្ងៃកើតហេតុទេ តែខ្លួនដឹងថា នៅថ្ងៃនោះខ្លួនរត់ម៉ូតូឌុបបានឮសូរស្រែក និងឮប្រាំវ១ ហើយមានក្មេងម្នាក់អាយុប្រហែល១៩ឆ្នាំស្រែកប្រាប់ថា ជួយផងគេកាប់ [redacted] ហើយខ្លួនក៏រត់ទៅមើល បានឃើញជនដៃដល់កំពុងចាក់លើ [redacted] ពេលឪពុកឈ្មោ [redacted] ចូលជួយកូនគាត់ ខ្លួនចូលជួយឃើញជនល្មើសជ្រុះទូលីវិសទៅលើដីហើយឪពុកឈ្មោ [redacted] ស្រែកឲ្យជួយចាប់ជនល្មើស ខ្លួនក៏ចាប់បានជនល្មើសចំងាយពីកន្លែងកើតហេតុប្រហែល១០ម៉ែត្រ។ ពេលខ្លួនចាប់ជនល្មើសបានភ្លាមៗមិនស្គាល់ឈ្មោះទេ ដល់ក្រោយមកទើបឮគេថាអ្នកនោះឈ្មោះ [redacted] ទៀតឈ្មោ [redacted] យក្រោយពីចាប់បានជនល្មើសបានក៏ត្រូវឈ្មោ [redacted] និងប្តីគាត់ចូលមករំដោះដោយស្រែកថា ឲ្យខ្លួនកុំចេះគេវាយចោរលួចកាច់កញ្ចក់ឡានទេ។បន្ទាប់មកខ្លួនយកជនរងគ្រោះទៅប៉ុស្តិ៍ប៉ូលីស តែឈាមច្រើនពេកគេឲ្យយកទៅពេទ្យសិនគឺខ្លួនជិះម៉ូតូតាមក្រោយរហូត។ ខ្លួនស្គាល់ឈ្មោ [redacted] ាយធ្លាប់ឌុបគាត់ឡើងឡានក្រុងជិះផ្សាររាត្រី ។ ពេលអង្គុយចាំម៉ូយនៅចំងាយប្រហែល២០ម៉ែត្រពីផ្ទះកើតហេតុហើយពេលឮស្រែកឲ្យជួយប្រហែល៥នាទីខ្លួនទៅឃើញជនល្មើសទី១ក្រៀក [redacted] ចាក់ ហើយខ្លួនឃើញឈ្មោ [redacted] ប្តីនៅចំងាយប្រហែល៦-៧ម៉ែត្រពីកន្លែងកើតហេតុ តែខ្លួនមិនដឹងថាជនល្មើសជាបងប្អូន [redacted] ទ ហើយបន្ទាប់ជនដៃដល់ទី២ ជាអ្នកកាន់ពូថៅបានរត់ចេញមកខ្លួនចាប់បានទើបឃើញវត្តមាន [redacted] និងប្តីគាត់នៅទីនោះចូលមករំដោះប្អូនគាត់ ប្រតាយប្រតប់គ្នាជាមួយខ្លួនទើបជនជាប់ចោទរត់រួច ។ ក្នុងពេលច្របូកច្របល់ខ្លួនមិនបានដឹងថាវត្តមានអ្នកក្នុងផ្ទះសំណាក់មានប៉ុន្មានទេ ហើយពីមុនមកខ្លួនស្គាល់មុ [redacted] មិនស្គាល់ឈ្មោះដល់ចប់រឿងទើបស្គាល់ឈ្មោះ។ពេលកើតហេតុមិនចាំម៉ោងទេ ហើយខ្លួនឃើញជនជាប់ចោទច្បាស់ដោយសារទីនោះមានភ្លើងអំពូលម៉ែត្រភ្លឺច្បាស់។

បានឃើញចម្លើយសាក្សីឈ្មោ [redacted] ឆ្លើយបញ្ជាក់ថា នៅថ្ងៃកើតហេតុម៉ោង៦ ទៅម៉ោង៧ ខ្លួនឃើញឈ្មោ [redacted] ម៉ូតូក៏សួរមកពីណា គាត់ឆ្លើយថាទិញម្ហូបបន្ទាប់មកឈ្មោះ [redacted] បុប្ផាដើរមកដល់ក៏ជជែកគ្នារឿងដីមួយសន្ទុះឮគេវាយគ្នាក្នុងផ្ទះសំណាក់។មួយសន្ទុះប្រហែល២០នាទី ស្រាប់តែមនុស្សប្រុសម្នាក់មកចោទថា [redacted] ាំគេមកវាយ ខ្លួនឆ្លើយតបថា [redacted] មិនបានបញ្ជាទេ។ ចំងាយពីផ្ទះខ្លួនទៅផ្ទះសំណា [redacted] ហែល២០ម៉ែត្រ ហើយពេលកំពុងកើតហេតុមានមនុស្សច្រើនស្រែកឆោឡោទើប [redacted] ដើរទៅឈរមើលក្រៅផ្ទះសំណាក់លើចិញ្ចើមថ្នល់ រួចត្រឡប់មកវិញតែពុំមាននិយាយអ្វីទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] ពេលទៅតវ៉ាជាមួយគ្នារឿងដីបឹងកក់ហើយខ្លួនមិនបានចេញពីផ្ទះមើលមុខអ្នកវាយគ្នាមិនច្បាស់នឹងនៅពីមុខផ្ទះខ្លួនពុំមានដាក់អំពូលភ្លើងទេ។

បានឃើញចម្លើយសាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា ខ្លួនស្គាល់ឈ្មោ [redacted] នៅភូមិជាមួយគ្នា តែមិនដែលស្គាល់ជនរងគ្រោះទេ ។ ខ្លួនមិនបាននៅកន្លែងកើតហេតុទេ ហើយចូលមកប់ភ្លឺពេលនេះពីរឿង [redacted] មិនមានប្អូនរស់នៅជាមួយទេ ព្រោះខ្លួនចេញចូលផ្ទះគាត់រាប់អានជាអ្នកភូមិជាមួយគ្នា។ខ្លួនមកនៅបឹងកក់ក្រោយ [redacted] មានផ្ទះចំងាយ២០ម៉ែត្រពីគ្នា ។



Scanned by CamScanner

បានឃើញចម្លើយសាក្សីឈ្មោ[redacted]ានឆ្លើយបញ្ជាក់ថា ខ្លួនមិនបាននៅកន្លែងកើតហេតុទេ ហើយមានទីលំនៅភូមិ២២និងជាប់របងជាមួយ[redacted]ខ្លួនមកធ្វើសាក្សីពីរឿងពុំដែលឃើញប្អូន[redacted]នៅជាមួយ៦-៧ឆ្នាំហើយ ។ ខ្លួនធ្លាប់ឃើញប្អូនប្រុសរបស់ឈ្មោ[redacted]ឆ្នាំ១៩៩៣ហើយចាប់តាំងពីគេអភិវឌ្ឍន៍មិនដែលឃើញទេ ។

តុលាការអាន ឯកសារ លិខិតភស្តុតាងព្យាបាលរបួសជនរងគ្រោះនិង វិក័យប័ត្រ

តុលាការបង្ហាញរូបថត

មេធាវីការពារដើមចោទផ្តល់សេចក្តីសន្និដ្ឋាន ៖

ក្រោយពីស្តាប់ការដេញដោលសាកសួរនិងការឆ្លើយតបរបស់សាក្សីខ្លួនសូមបញ្ជាក់ពីអង្គហេតុដូចតទៅ៖ នៅថ្ងៃទី០៧-៨-២០១២ វេលាម៉ោង៧យប់មានករណីហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស នៅផ្ទះសំណាក់ចាន់ បុប្ផា ហើយកូនក្តីខ្លួនបានប្តឹងពីមនុស្ស៤នាក់ដែលជាជនជាប់ចោទនេះ។ ឈ្មោ[redacted]ប្តីបានបាត់កញ្ចក់ឡានសង្ស័យលើកូនក្តីខ្លួនហើយឲ្យប្អូនគាត់ធ្វើសកម្មភាពវាយលើកូនក្តីខ្លួនជាជនរងគ្រោះ ។មានសាក្សីក្មេងម្នាក់ប្រាប់ថា [redacted]កថា វាយចោរប៉ុណ្ណោះហើយមានសាក្សីបានឃើញសាក្សីឈ្មោ[redacted]ចាប់បានឈ្មោ[redacted]និងប្តីមករំដោះ។ ចំណែកសាក្សីមកឆ្លើយពេលនេះថា ផ្ទះគាត់ចំងាយ២០ម៉ែត្រគាត់មើលមិនច្បាស់ទេ ហើយសាក្សី២នាក់ទៀតថា មិនមានឈ្មោះ[redacted]នៅទីនោះទេ គឺគាត់មិនដឹងពីជីវភាពក្រុមគ្រួសារនេះទេ ដូចនេះសាក្សីគាត់មិនអាចយកជាការបានទេ។ល[redacted]ានបញ្ជាក់ហើយថាប្អូនគាត់ជាមនុស្សប្រដៅមិនបានដូចនេះស៊ីសង្វាក់និងអំពើប្រព្រឹត្ត ។ចំពោះចម្លើយកូនក្តីខ្លួនថាមិន[redacted]ន តែដល់ក្រោយកើតហេតុប្រហែល១០នាទី ទើបមានគេប្រាប់ថាឈ្មោះនេះ ។

តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋាន៖

ក្រោយពីបានស្តាប់របាយការណ៍ ក្រោយពីបានស្តាប់ការសាកសួរ ក្នុងនោះមានជនជាប់ចោទ៤នាក់ ជាប់ចោទពីបទប្រើហិង្សាមានស្ថានទម្ងន់ទោស ហើយតំណាងមហាអយ្យការពិនិត្យឃើញថា អង្គហេតុនេះ បានកើតឡើងដោយ[redacted]ានវាយដំលើឈ[redacted]តាមការចង្អុលបង្ហាញ[redacted]ណ្តាលឲ្យមានរបួសដូចរូបភាពបង្ហាញពេលនេះ។តំណាងមហាអយ្យការកត់សំគាល់ចម្លើយឈ្មោះ[redacted]គាត់មិនមែនជាជនដៃដល់ទេ តែគាត់ជាអ្នកផ្តើមឲ្យមានអង្គហេតុនេះ។ ជនរងគ្រោះឈ្មោ[redacted]របួសនឹងទូលីវ[redacted]ងរបួសនឹងពូថៅដោយសារឈ្មោះ[redacted]ាអ្នកបង្ក ហើយជនរងគ្រោះទាំងពីរនាក់បានត្រូវជួយសង្គ្រោះភ្លាមៗ យកទៅមន្ទីរពេទ្យ ដល់ថ្ងៃបន្ទាប់ទើបប្តឹងពីរឿងនេះ។សុំក្រុមប្រឹក្សាពិចារណាលើថ្លៃព្យាបាលជនរងគ្រោះព្រោះ វិក័យបត្របញ្ជាក់ពីរបួសពិតប្រាកដ ហើយពេលនេះជនរងគ្រោះបញ្ជាក់ថា គាត់មានការភ្លេចភ្លាំង។រឿងនេះ សុំក្រុមប្រឹក្សាពិនិត្យមាត្រា២៣,២៨ក្រមថ្មីទាក់ទិននឹងអ្នកសមគំនិត តែការលើកឡើងនេះមិនមែនមានន័យថា ជនជាប់ចោទមានទោសទណ្ឌដូចគ្នាទេ ហើយច្បាប់បានតំរូវឲ្យចៅក្រមមានឆន្ទានុសិទ្ធិក្នុងការកំរិតទណ្ឌកម្ម សេចក្តីពន្យល់របស់ក្រសួងយុត្តិធម៌ពន្យល់ពីមាត្រា២៨ក្រមថ្មីនេះដែរ។ សុំក្រុមប្រឹក្សាពិចារណាចម្លើយសាក្សីជាអ្នករត់ម៉ូតូឌុបគឺគាត់ស្គាល់អតិជនច្បាស់ទោះយប់ឬថ្ងៃក៏ដោយនិងសា[redacted]ក៏សុំពិចារណាចម្លើយរបស់គាត់ដែរ។ តំណាងមហាអយ្យការមានជំនឿជឿជាក់ថា ក្រុមប្រឹក្សានឹងផ្តល់ការសម្រេចសេចក្តី



Scanned by CamScanner

ដោយយុត្តិធម៌ជាទីបំផុត ដើម្បីទទួលយកបានទាំងជនរងគ្រោះនិងជនជាប់ចោទ ។ជាគោលការណ៍តំណាងមហាអយ្យការត្រូវរកជនល្មើសដើម្បីផ្តន្ទាទោស។ តំណាងមហាអយ្យការមានចម្ងល់ថា រដ្ឋាភិបាលយកចិត្តទុកដាក់លើស្ត្រី ចុះហេតុអីរឿងនេះឲ្យបុរសនៅរក្សាកូន ស្ត្រីបែរជានៅរងទណ្ឌកម្ម ។ផ្អែកតាមមាត្រា២៨ក្រមថ្មីសូមពិចារណាថា តើការផ្តន្ទាទោសដូចតាវី ឬអត់ ។

មេធាវីប[redacted]បចក្តីសន្និដ្ឋាន៖

អង្គហេតុបានដឹងឮតាមការសួរនាំរួចហើយ បើតាមសំណុំរឿងមានអំពើហឹង្សាកើតឡើង និងមានរបួសពិតមែន។ឈ្មោ[redacted]ងឈ្មោះ[redacted]នប្តឹងពីកូនក្តីខ្លួនទាំងពីនាក់និងឈ្មោះ[redacted] និ[redacted]កូនក្តីខ្លួនបានបញ្ជាក់ថា គាត់មិនបានចូលរួមប្រព្រឹត្តទេ ហើយមានសាក្សីឈ្មោះ ផាន [redacted]និ[redacted]កំពុងនិយាយគ្នារឿងដីធ្លីមិនបានប៉ុន្មានផងស្រាប់តែឮផ្ទុះហេតុនៅផ្ទះសំណាក់ចាន់បុប្ផា។ អំពើនេះកើតនៅក្រោយខ្នងកូនក្តីខ្លួនម្ខាងថ្នល់ម្នាក់ គាត់ទៅមើលរួចបានត្រឡប់មកឈរកន្លែ[redacted]ញ ទើបមានគេមកចោទគាត់ ហើយ[redacted]បានតបតថាកុំចេះតែចោទគាត់ៗនៅទីនេះរហូត ។ ខ្លួនសុំតម្កល់សេចក្តីសន្និដ្ឋានរបស់ខ្លួនដដែល ដោយកូនក្តីមិនបានប្រព្រឹត្តព្រោះចេតនាគ្មានបានគ្រោងទុក ដូចជាគាត់នៅឈរនិយាយជាមួ[redacted]។ចំពោះចម្លើយដាក់បន្ទុកលើកូនក្តីខ្លួន តាមការសន្និដ្ឋានគឺឆ្លើយដោយមិនស្គាល់អត្តសញ្ញាណជនប្រព្រឹត្តបទល្មើសទេ ពួកគាត់ឮគេថា ដូច្នេះជាវិមតិសង្ស័យ។ បើពិនិត្យនីត្យានុកូល គឺចោទមិនត្រឹមត្រូវ មិនចំមនុស្ស ខ្លួនសង្ស័យថាផឹកស្រា៨ទៅ៩ម៉ោងអាចឈ្លោះគ្នាវាយគ្នា តែបើប្អូនកូនក្តីខ្លួនជាអ្នកវាយគួរឲ្យអ្នកប្រព្រឹត្តទទួលខុសត្រូវយោងតាមមាត្រា២៨ក្រមព្រហ្មទណ្ឌ។ ចំពោះអត្តសញ្ញាណអ្នកប្រព្រឹត្តបទល្មើស សាក្សីដែលដាក់មកមិនស៊ីគ្នានឹងអត្តសញ្ញាណដែលឪពុក ម្តាយគាត់ប្រាប់ទេ។ គឺពុំមានបទល្មើសបើគ្មានចេតនាប្រព្រឹត្ត ដូចមានការបំភ្លឺរបស់សាក្សី [redacted]សុំក្រុមប្រឹក្សាកត់សំគាល់ពីឪពុកជនរងគ្រោះរត់មកចង្អុលកូនក្តីខ្លួនគឺគ្រាន់តែជាការសង្ស័យប៉ុណ្ណោះ។ ចពោះសំណងការខូចខាតមានតិចតួចអស់២០ដុល្លា តែសាលាដំបូងសំរេចឲ្យកូនក្តីខ្លួនសងដល់មួយម៉ឺនប្រាំពាន់ដុល្លា សុំពិចារណាឡើងវិញ ។ ទាក់ទងយោបល់តំណាងមហាអយ្យការបទសមត់និតមិនបានចោទប្រកាន់ទេ ហើយកូនក្តីខ្លួនមិនពាក់ពន្ធ័មាត្រា២៨ក្រមព្រហ្មទណ្ឌ័នេះដែរ ។ សុំមោយភាពសាលក្រមនិងសុំលើកលែងចោទប្រកាន់កូនក្តីខ្លួន ដោយកូនក្តីខ្លួនជាប់ពន្ធនាគារជាង៩ខែហើយសុំដោះលែង។

តុលាការអាន ឯកសារ លិខិតភស្តុតាងព្យាបាលរបួសជនរងគ្រោះនិង វិក័យប័ត្រ

តុលាការបង្ហាញរូបថតជនរងគ្រោះ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយបង្អស់របស់ជនជាប់ចោទ



Scanned by CamScanner

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ។

**<u>យល់ឃើញថា</u>**

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៣-០១-២០១៣ របស់មេធាវីទទួលសិទ្ធិប្តឹងឧទ្ធរណ៍ឱ្យជនជាប់ចោទឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១០៧ "ឃ" ចុះថ្ងៃទី ២៧-១២-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌសាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន។

២-ជនជាប់ចោទបានឆ្លើយបដិសេធការចោទប្រកាន់របស់តំណាងអយ្យការ ប៉ុន្តែទទួលស្គាល់ថាមានវត្តមាននៅក្បែរបរិវេណកន្លែងកើតហេតុចម្ងាយប្រហែល១០ម៉ែត្រ បានឮសម្លេងឈ្លោះប្រកែកគ្នាហើយបានដើរទៅមើល និងបានស្រែកឱ្យគេជួយបំបែកនៅពេលមានការប្រតាយប្រតប់គ្នា ប៉ុន្តែមិនបានបញ្ជាឱ្យវាយឬជួយរំដោះជនដៃដល់ទេ ។ ជនជាប់ចោទទទួលស្គាល់ថា មុនថ្ងៃកើតហេតុវាយតប់នេះ ខ្លួនធ្លាប់បាត់កញ្ចក់ឡានចំនួន៣ដងហើយមិនដែលមានទំនាស់ជាមួយជនរងគ្រោះទេ។

៣-ចម្លើយរបស់ជនរងគ្រោះ[redacted]បានឆ្លើយបញ្ជាក់ថា មុនពេលមានការវាយតប់មានមនុស្ស៤រូបដើរចូលមកកន្លែងខ្លួនកំពុងអង្គុយដោយពីរនាក់ប្តីប្រពន្ធចូលមកមុនហើយចង្អុលមុខខ្លួន ។ បន្ទាប់មកប្អូនទាំងពីរចូលមកតាមក្រោយចាប់វាយពួកខ្លួន ដោយឈ្មោះ[redacted] ចាក់ខ្លួននឹងទូណឺវីសត្រូវច្រើនកន្លែងហើយម្នាក់ទៀតកាប់ឈ្មោ[redacted] ត្រូវពីរពូថៅ ។ បន្ទាប់មកជនជាប់ចោទបានរត់ចេញមកក្រៅត្រូវបានឈ[redacted]ចាប់ជាប់ប៉ុន្តែឈ្មោះ[redacted]រត់មកប្រឡេះដៃឱ្យជនជាប់ចោទរត់គេចខ្លួន។ សាក្សីដែលបានឃើញហេតុការណ៍ឈ្មោ[redacted]បានអះអាងប្រហាក់ប្រហែលគ្នា។

៤-តាមចម្លើយរបស់ជនរងគ្រោះបានបញ្ជាក់ថា[redacted] នាំប្អូនទៅវាយពួកខ្លួនដោយយល់ថាពួកខ្លួនទាំងពីរនាក់ជាអ្នកលួចកញ្ចក់ឡានដែលបានបាត់កន្លងមក។ជនរងគ្រោះពុំធ្លាប់មានគំនុំជាមួយជនជាប់ចោទហើយក៏គ្មានគំនុំជាមួយឈ្មោ[redacted]ដែរ។ពាក្យសំដីដែលជនរងគ្រោះឮជនជាប់ចោទប្រាប់ទៅឈ្មោ[redacted]ថា "ខ្លួនវាយតែពួកចោរលួចកញ្ចក់ឡាន" មានលក្ខណៈស៊ីសង្វាក់ទៅនឹងហេតុការណ៍ដែលជនជាប់ចោទបានបាត់កញ្ចក់ឡាន៣លើក ហើយលើកទី៣ គឺបាត់មុនពេលកើតហេតុវាយតប់ចំនួនប្រហែល១០ថ្ងៃ ។ ម៉្យាងទៀត ពេលជនជាប់ចោទបាត់កញ្ចក់ឡាន ជនរងគ្រោះពុំបានដឹងទេ ហេតុនេះសំដីដែលជនរងគ្រោះឮជនជាប់ចោទពោលថា "ខ្លួនវាយតែពួកចោរលួចកញ្ចក់ឡាន" អាចឱ្យតុលាការជឿបានថា ការបាត់កញ្ចក់ឡានជាដើមចមនាំឱ្យមានការប្រើអំពើហិង្សាក្នុងរឿងនេះ។

៥-ជនជាប់ចោទអះអាងថាការចោទប្រកាន់លើពួកខ្លួនកើតឡើងដោយសារការរៀបចំរបស់សមត្ថកិច្ចដើម្បីដាក់បន្ទុកលើខ្លួន ប៉ុន្តែឯកសារនៅក្នុងសំណុំរឿងឃើញថា ជនរងគ្រោះត្រូវបានគេវាយឱ្យរបួសពិតប្រាកដ ហើយដាក់ពាក្យបណ្តឹងចំឈ្មោះជនជាប់ចោទនៅថ្ងៃបន្ទាប់។

៦-ជនជាប់ចោទនិងមេធាវីតែងបដិសេធថា ជនដៃដល់មិនមែនជាប្អូនខ្លួន ប៉ុន្តែភ្លាមៗក្រោយពេលកើតហេតុឪពុកជនរងគ្រោះរត់មកចង្អុលមុខអ្នកស្រី[redacted]បាននាំប្អូនមកវាយកូនខ្លួនហើយចំណុចនេះជនជាប់ចោទក៏ទទួលស្គាល់ និងមានសាក្សីឃើញផងដែរ ។ ការចង្អុលលើជនជាប់ចោទដោយឪពុកជន



Scanned by CamScanner

រងគ្រោះបានបញ្ជាក់ច្បាស់ពីការស្គាល់អត្តសញ្ញាណជនបង្កហេតុដែលមានលក្ខណៈស៊ីសង្វាក់នឹងចម្លើយសាក្សី [redacted]ួរឱ្យជឿបាន ព្រោះនៅពេលកើតហេតុមានអំពូលភ្លើងភ្លឺមានមនុស្សច្រើននាក់នៅទីនោះមិនអាចធ្វើការចោទប្រកាន់លើមនុស្សដោយមិនបានស្គាល់ឡើយ ព្រោះអ្នកនៅទីនោះអាចធ្វើជាសាក្សីបដិសេធបាន។ នៅថ្ងៃកើតហេតុ មានជនរងគ្រោះឪពុកជនរងគ្រោះ និងសាក្សីស្គាល់ឈ្មោ[redacted]ស់ ហើយប្រជាពលរដ្ឋដែលផ្អើលឆោឡោទៅមើលអាចកំណត់អត្តសញ្ញាណជនជាប់ចោទមកប្រាប់ជនរងគ្រោះថា ជាប្អូនរបស់ឈ្មោ[redacted] ព្រោះធ្លាប់រស់នៅក្នុងភូមិជាមួយគ្នា ទើបតែចាកចេញទៅនៅកន្លែងផ្សេងមុនពេលកើតហេតុប្រហែល២ឆ្នាំ។

ករណីឈ្មោះ [redacted]ានសាក្សីបដិសេធអត្តសញ្ញាណទេ ហើយនៅសាលាដំបូងក៏គ្មានភាគីណាមួយលើកឡើងពីអត្តសញ្ញាណជនដៃដល់ថា មិនមែនជាយ[redacted]ម [redacted]ដែរ។ ឯកសារតាំងពីដំណាក់កាលស៊ើបអង្កេតរហូតដល់នីតិវិធីនៅសាលាឧទ្ធរណ៍ពុំមានឯកសារតវ៉ាពីអត្តសញ្ញាណនេះទេ។ ជនជាប់ចោទបានដាក់សាក្សីពីររូបដើម្បីឆ្លើយដោះបន្ទុកប៉ុន្តែសាក្សីទាំងពីររូបមិនបាននៅកន្លែងកើតហេតុទេ ហើយគ្រាន់តែដឹង[redacted]ននៅផ្ទះជាមួយអ្នកស្រី [redacted]តប៉ុណ្ណោះ ។

៧-សកម្មភាពរបស់អ្នកស្រ[redacted]លនៅកន្លែងកើតហេតុ ហើយមានសាក្សីឃើញចង្អុលសំដៅជនរងគ្រោះដើម្បីឱ្យប្អូនវាយព្រមទាំងជួយរំដោះប្អូនពីការចាប់ឃាត់ខ្លួន ដោយសាក្សីនៅកន្លែងកើតហេតុបានបង្ហាញពីចេតនាចូលរួមប្រព្រឹត្តបទល្មើសក្នុងឋានៈជាអ្នកផ្តើមគំនិត យោងតាមមាត្រា២៨ នៃក្រមព្រហ្មទណ្ឌ។

៨-តាមការសំអាងហេតុទី២ដល់ទី៧ខាងលើអាចកំណត់បានថា ជនជាប់ចោ[redacted]និង [redacted]ជនដៃដល់ក្នុងការបង្ករបួសដល់ជនរងគ្រោះដូចការចោទប្រកាន់ [redacted] បញ្ជាឱ្យវាយនិងជួយរំដោះជនជាប់ចោទពេលត្រូវគេចាប់ជាប់។

៩-ជនរងគ្រោះពិតជាមានរបួសដូចការអះអាង នាពេលសវនាការមានរូបថតជាភស្តុតាងនិងស្លាកស្នាមលើដងខ្លួន ប៉ុន្តែតាមវិក័យប័ត្រសម្រាកពេទ្យនិងឯកសារពិនិត្យអមវេជ្ជសាស្ត្រផ្សេងៗទៀតមានការចំណាយតិចជាងការប្តឹងសុំច្រើនកំរិត ដែលគប្បីតុលាការផ្ទៀងផ្ទាត់ឡើងវិញលើប្រាក់សំណងដើម្បីឱ្យមានលក្ខណៈសមាមាត្រនិងសមរម្យ។

១០-ជនជាប់ចោទមិនធ្លាប់ត្រូវបានផ្តន្ទាទោសនិងមិនមែនជាជនដៃដល់គប្បីតុលាការពិចារណាបន្ថយទណ្ឌកម្មឱ្យសមាមាត្រនឹងអំពើរបស់ខ្លួន។

១១-សាលក្រមព្រហ្មទណ្ឌលេខ១០៧" យ " ចុះថ្ងៃទី២៧-១២-២០១២របស់សាលាដំបូងរាជធានីភ្នំពេញបានសម្រេចត្រឹមត្រូវហើយគប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមខាងលើទុកជាបានការ លើកលែងតែចំណុចដូចបានសំអាងហេតុទី៩ និងទី១០ខាងលើដែលត្រូវកែតម្រូវឡើងវិញ។

## ខនិច្ឆ័យសេចក្ត

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៣-០១-២០១៣ របស់មេធាវីទទួលសិទ្ធិប្តឹងឧទ្ធរណ៍ឱ្យជនជាប់ចោទឈ្មោ[redacted]ត្រឹមត្រូវតាមទម្រង់ច្បាប់។



Scanned by CamScanner

២-កែប្រែបទចោទប្រកាន់លើឈ្មោ[redacted]បទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស មកជាបទផ្តើមគំនិតក្នុងអំពើប្រព្រឹត្តហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស តាមមាត្រា២៨ និងមាត្រា២១៨នៃក្រមព្រហ្មទណ្ឌ។

៣-តំកល់សាលក្រមព្រហ្មទណ្ឌលេខ១០៧ "ឃ" ចុះថ្ងៃទី២៧-១២-២០១២របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ លើកលែងតែ

-ចំណុចទី១នៃសេចក្តីសម្រេចត្រង់- ផ្តន្ទាទោស[redacted]-ផ្តន្ទាទោស[redacted]ន្ធនាគារ៣ឆ្នាំ ប៉ុន្តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល២ឆ្នាំ ទោសដែលនៅសល់១ឆ្នាំ ត្រូវព្យួរធម្មតាតាមមាត្រា១០៨នៃក្រមព្រហ្មទណ្ឌ-។

-ចំណុចទី២នៃសេចក្តីសម្រេចត្រង់ - បង្គាប់ឱ្យជនជាប់ចោទទាំង៤រូប រួមគ្នាសងសំណងអន្តរាយនិងជម្ងឺចិត្តដល់ជនរងគ្រោះឈ្មោះង៉ែត ចិត្ត និងឈ្មោះវ៉ាត ថៃសេង ក្នុងម្នាក់ៗចំនួន៣០លានរៀល -ត្រូវកែប្រែជា-បង្គាប់ឱ្យជនជាប់ចោទទាំង៤រូប រួមគ្នាសងសំណងអន្តរាយនិងជម្ងឺចិត្តដល់ជនរងគ្រោះឈ្មោះង៉ែត ចិត្ត និងឈ្មោះ វ៉ាត ថៃសេង ក្នុងម្នាក់ៗចំនួន១០លានរៀល (ដប់លានរៀលគត់) ។

ចំណុចដទៃទៀតនៃសេចក្តីសម្រេចនៅរក្សាទុកជាបានការដដែល។

៤-បន្តឃុំខ្លួនជនជាប់ចោទឈ្មោ[redacted]លើតាមនីតិវិធី និងបន្តចាប់ខ្លួនជនជាប់ចោទឈ្មោ[redacted]មដីកាបង្គាប់ឱ្យចាប់-ឃុំខ្លួនលេខ៦២៨តព្រចុះថ្ងៃទី៣១-១២-២០១២ និងលេខ៦២៩តព្រ ចុះថ្ងៃទី៣១-១២-២០១២ របស់ចៅក្រមជំនុំជម្រះសាលាដំបូងរាជធានីភ្នំពេញ។

សាលដីកានេះជំនុំជំរះចំពោះមុខមេធាវីការពារជនជាប់ចោទជនជាប់ចោទឈ្មោ[redacted] ឈ្មោះ [redacted]ធាវីការពារជនរងគ្រោះនិងជនរងគ្រោះ ប្រកាសជាសាធារណៈ នៅថ្ងៃទី១៨ខែមិថុនា ឆ្នាំ២០១៣ បើកសិទ្ធិប្តឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| --- | --- | --- |
| ហត្ថលេខា[redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

ចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ០៧ ខែ[illegible] ឆ្នាំ២០១៣

ក្រឡាបញ្ជី

ភ្នំពេញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned by CamScanner